ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 03 / 2015
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
**E1/265**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥

## **សវនាការលើអង្គសេចក្តី - ថ្ងៃ ២៥៦**

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Matthew McCARTHY**

| <u>**កំណត់ហេតុអ្នកចូលរួម**</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ាង, Mathew McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Travis FARR, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក វ៉េន ពៅ, លោកស្រី ទី ស្រីនណា |

| |
|---|
| សាក្សី/ដើមបណ្តឹង ៖ សៅ ប៊ាន (2-TCW-807) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធារី |
| ផ្សេងៗ៖ លោក Sheriffo JAMMEH, កញ្ញា Kerri MILES, លោក នូ មនោរ័ត្ន, កញ្ញា សុក សុភ័គមណីកា, លោក Mario D'ALESSANDRO |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០៤ | បញ្ចប់ម៉ោង៖ ១៤.៤១ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១២ | បញ្ចប់ម៉ោង៖ ១០.៣៦ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៦ | បញ្ចប់ម៉ោង៖ ១៣.៤៣ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.១២ | បញ្ចប់ម៉ោង៖ ១៤.៣៩ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០២ ម៉ោង និង ៣៨ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៤ | ០៩.០៦ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៦ | ០៩.០៨ |
| ការតាំងសំណួរទៅកាន់សាក្សី សៅ ប៊ាន (2-TCW-807) | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា | ០៩.០៨<br>១០.៤២<br>១១.១៥ | ១០.៤២<br>១១.១៥<br>១៤.០៧ |
| សំណើរបស់មេធាវីការពារក្តី នួន ជា សុំបង្ហាញឯកសារដែលមិនបានដាក់ចូលឃ្លាំងផ្ទុកឯកសារ (Interface) | មេធាវីការពារក្តី នួន ជា<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១៣.៤៣ | ១៣.៥៦ |
| ការប្រកាសផ្អាកសវនាការ | អង្គជំនុំជម្រះ | ១៣.៣៩ | ១៤.៤១ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថាគ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ និងនិងអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួន ស្ថិតនៅខាងក្រោមសាលសវនាការ អនុលោមតាមវិធាន ៨១ (៥) នៃវិធានផ្ទៃក្នុង។

**ការតាំងសំណួរទៅកាន់សាក្សី សៅ ប៊ាន (2-TCW-807)**

សហព្រះរាជអាជ្ញាបានតាំងសំនួរទៅកាន់សាក្សី សៅ ប៊ាន។ បន្ទាប់មក មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីការពារក្តី នួន ជា បានតាំងសំណួរបន្ត។ ដោយឡែក មេធាវីការពារក្តី ខៀវ សំផន ពុំមានសំណួរសួរទៅកាន់សាក្សីនោះទេ។

**សំណើរបស់មេធាវីការពារក្តី នួន ជា សុំបង្ហាញឯកសារដែលមិនបានដាក់ចូលឃ្លាំងផ្ទុកឯកសារ (Interface)**

មេធាវីការពារក្តី នួន ជា ស្នើសុំដាក់បង្ហាញដល់សាក្សីនូវឯកសារដែលខ្លួនមិនបានដាក់បញ្ចូលទៅក្នុងឃ្លាំងផ្ទុកឯកសារប្រចាំថ្ងៃ (Interface) ជាមុន។ សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខមិនបានជំទាស់នោះទេ គ្រាន់តែធ្វើការកត់សម្គាល់ថា នេះជាកាលៈទេសៈពិសេស។ ភាគីទាំងអស់យល់ស្របទៅលើសំណើដែលស្នើសុំឲ្យអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចជាគោលការណ៍ទៅលើបញ្ហានេះ។

**ការប្រកាសផ្អាកកិច្ចនីតិវិធីសវនាការ**

អង្គជំនុំជម្រះប្រកាសផ្អាកសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-944 ដល់ថ្ងៃ ១៩ ខែ កុម្ភៈ ឆ្នាំ២០១៥ វេលាម៉ោង ០៩ ព្រឹក ដើម្បីពិភាក្សាលើសំណើសុំវិធានការការពារដែលស្នើឡើងដោយសាក្សី 2-TCW-944។ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគី និងសាធារណជនថា សវនាការថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ នឹងបន្តស្តាប់សក្ខីកម្មសាក្សី ស្រី ថន (2-TCW-944)។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| លេខ E3 | លេខ កសចស | ERN (KH, ENG, FR) | ចំណងជើងឯកសារ | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|---|
| E3/5518 | | 00408312-00408320<br>00413895-00413902<br>00702550-00702558 | [Corrected 1] Written Record of Interview of SĂO Hean | P | 00408317<br>00408318<br>00408319 | 00413901<br>00413901<br>00413902 | 00702555<br>00702556<br>00702557 |
| E3/2437 | | 00271003-00271003<br>00366707-00366707<br>00623848-00623848 | Report on Amrit Mart to District 105 | P | 00271003 | 00366707 | 00623848 |
| E3/4127 | | 00270803-00270810<br>00362227-00362233<br>00632503-00632507 | Report on people sent to education department 105 | P | 00270806 | 00362229 | 00632505 |
| E3/2057 | | 00079135-00079147<br>00276581-00276589<br>00848198-00848203 | Report to the Education Committee on the enemy in Tram Kak District | P | 00079142<br>00079143 | 00276586<br>00276587 | 00848201<br>00848202 |
| E3/746 | | 00064485-00064511<br>00428289-00428307<br>00611870-00611892 | CPK Magazine entitled: " The Revolutionary Flag", Issue 7, July 1978 (FULL) | P | 0064504 | 00428305 | 00611886 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ហើយបង្គាប់អ្នកជំនាញតំឡើងឧបករណ៍សោធទស្សន៍សម្រាប់ជនជាប់

ចោទ នួន ជា ដើម្បីបន្តតាមដានសវនាការនៅបន្ទប់ឃុំខ្លួនខាងក្រោម។

- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ។

| **<u>កាលវេលាសវនាការបន្ត</u>** |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ីទ[illegible]** **Matthew McCARTHY**